00640677

E9/4

**នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង**
**នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា**

**ព័ត៌មានពិស្តារនៃការដាក់ឯកសារ**

| | | |
|---|---|---|
| **សំណុំរឿងលេខ** | : | ០០២/១៩-០៩-២០០៧-អ.វ.ត.ក/អ.ជ.ស.ដ |
| **ដាក់ទៅ** | : | អង្គជំនុំជម្រះសាលាដំបូង |
| **ថ្ងៃដាក់** | : | ថ្ងៃទី២៨ ខែមករា ឆ្នាំ២០១១ |
| **ភាគីអ្នកដាក់** | : | សហព្រះរាជអាជ្ញា |
| **ភាសាដើម** | : | អង់គ្លេស |

**ឯកសារទទួល**
DOCUMENT RECEIVED/DOCUMENT REÇU
ថ្ងៃ ខែ ឆ្នាំ (Date of receipt/Date de reception): 28 / 01 / 2011
ម៉ោង (Time/Heure): 15 : 30
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: Uch Arun

**ចំណាត់ថ្នាក់ឯកសារ**

ប្រភេទឯកសារដែលស្នើឡើងដោយភាគីដាក់ឯកសារ: **សាធារណៈ**

ចំណាត់ថ្នាក់ឯកសារកំណត់ដោយការិ.សហចៅក្រមស៊ើបអង្កេត: សាធារណៈ / Public

ប្រភេទនៃចំណាត់ថ្នាក់ឯកសារ:

ការពិនិត្យឯកសារបណ្តោះអាសន្នឡើងវិញ:

ឈ្មោះមន្ត្រីដែលបានពិនិត្យ:

ហត្ថលេខា:

---

**បញ្ជីឈ្មោះអ្នកជំនាញ សាក្សី និងដើមបណ្តឹងរដ្ឋប្បវេណី របស់សហព្រះរាជអាជ្ញា**
**ប្រមូលផ្តុំតាមប្រធានបទសម្រាប់ទី១, ទី២, ទី៣, ទី៣ក, ទី៤ និង ទី៥**

---

**អ្នកដាក់ឯកសារ:**

**សហព្រះរាជអាជ្ញា:**
លោកស្រី ជា លាង
លោក Andrew CAYLEY

**អ្នកទទួលឯកសារ:**

**អង្គជំនុំជម្រះសាលាដំបូង:**
ចៅក្រម និល ណុន, ប្រធាន
ចៅក្រម Silvia CARTWRIGHT
ចៅក្រម យ៉ា សុខន
ចៅក្រម Jean-Marc LAVERGNE
ចៅក្រម ធូ មណី

**ជនត្រូវចោទ និង ក្រុមមេធាវី:**
នួន ជា
លោក សុន អរុណ
លោក Michiel PESTMAN
លោក Victor Koppe

E9/4

*សំណុំរឿងលេខៈ ០០២/១៩-០៩-២០០៧-អ.វ.ត.ក/អ.ជ.ស.ជ*

**<u>សហមេធាវីនាំមុខតំណាងដើមបណ្តឹង</u>**

**<u>រដ្ឋប្បវេណីៈ</u>**

លោក ពេជ អង្គ

Elisabeth SIMONNEAU FORT

**អៀង សារី**

លោក អាង ឧត្តម

លោក Michael G.KARNAVAS

**អៀង ធីរិទ្ធ**

លោក ផាត់ ពៅស៊ាង

កញ្ញា Diana ELLIS QC

**ខៀវ សំផន**

លោក សរ សុវាន

លោក Jacques VERGÈS

លោក Philippe GRÉCIANO

## ១. សេចក្តីផ្តើម

១. ដោយអនុលោមតាមវិធាន៨០ នៃវិធានផ្ទៃក្នុង[1] និងដីកាបង្គាប់ឱ្យភាគីដាក់សម្ភារៈដើម្បីរៀបចំសវនាការ របស់អង្គជំនុំជម្រះសាលាដំបូង ចុះថ្ងៃទី១៧ ខែមករា ឆ្នាំ២០១១[2] សហព្រះរាជអាជ្ញាស្នើដាក់ឧបសម្ពន្ធសម្ងាត់នានាចំនួនប្រាំមួយ ដែលមានផ្ទុកទៅដោយបញ្ជីឈ្មោះអ្នកជំនាញ (**ឧបសម្ពន្ធទី២**), បញ្ជីឈ្មោះសាក្សី (**ឧបសម្ពន្ធទី៣ និង ទី៣ក**) និងបញ្ជីឈ្មោះដើមបណ្តឹងរដ្ឋប្បវេណី (**ឧបសម្ពន្ធទី៤**) ដែលសហព្រះរាជអាជ្ញាស្នើសុំឱ្យធ្វើការកោះហៅ ដើម្បីចូលមកបង្ហាញខ្លួននៅពេលសវនាការ។ បញ្ជីឈ្មោះទាំងនេះ ត្រូវបានរៀបតាមលំដាប់លំដោយតាមតួអក្ខរៈនៃនាមត្រកូល។ **ឧបសម្ពន្ធទី១** គឺជាបញ្ជីឈ្មោះបញ្ចូលគ្នាមួយ ដែលមានផ្ទុកទៅដោយឈ្មោះបុគ្គលទាំងអស់ដែលមាននៅក្នុង **ឧបសម្ពន្ធទី២, ទី៣, ទី៣ក និង ទី៤** ទៅតាមលេខរៀងដែលសហព្រះរាជអាជ្ញាដាក់ជូនដោយស្នើសុំឱ្យចូលមកបង្ហាញខ្លួននៅពេលសវនាការ។ នៅក្នុង**ឧបសម្ពន្ធទី៥** មានឈ្មោះបន្ថែមនៃបុគ្គលដែលសហព្រះរាជអាជ្ញា អាចនឹងស្នើសុំឱ្យកោះហៅ តែក្នុងករណីដែលមានការចាំបាច់ត្រូវបញ្ជាក់យថាភូតលើឯកសារមួយចំនួនជាបន្ថែមទៀត ឬឱ្យស្តាប់ចម្លើយនានាតែប៉ុណ្ណោះ។

## ២. ឧបសម្ពន្ធទី១ ដល់ ទី៤

*មាតិការឿង*

២. **ឧបសម្ពន្ធទី២, ទី៣, ទី៣ក, និង ទី៤** មានផ្ទុកឈ្មោះ និងចំណុចសម្គាល់ជាក់លាក់របស់ អ្នកជំនាញចំនួន ១៦នាក់, សាក្សីចំនួន ២៤៧នាក់ និងដើមបណ្តឹងរដ្ឋប្បវេណីចំនួន ៣២នាក់។ ចំណុចសម្គាល់ជាក់លាក់ផ្សេងៗទៀតរបស់បុគ្គលម្នាក់ៗ ដែលសហព្រះរាជអាជ្ញាអាចទទួលបាននូវព័ត៌មានទាំងនេះ រួមមាន៖ ភេទ ទីកន្លែងកំណើត និង ថ្ងៃខែឆ្នាំកំណើត, អាសយដ្ឋានបច្ចុប្បន្ន ឬអាសយដ្ឋានលំអិត, លេខយោងឯកសារនៃកំណត់ហេតុស្តាប់ចម្លើយពាក់ព័ន្ធបំផុតរបស់បុគ្គលនោះ[3], ប្រភេទសម្បថ

[1] វិធានផ្ទៃក្នុងនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា, (វិសោធនកម្មលើកទី ៦) (បានធ្វើវិសោធនកម្ម នៅថ្ងៃទី១៧ ខែកញ្ញា ឆ្នាំ២០១០) (វិធានផ្ទៃក្នុងអ.វ.ត.ក.), វិធាន ៨០ ។

[2] ដីកាបង្គាប់ឱ្យភាគីដាក់សម្ភារៈដើម្បីរៀបចំសវនាការ, អង្គជំនុំជម្រះសាលាដំបូង, សំណុំរឿងលេខ: ០០២/១៩-០៩-២០០៧-អ.វ.ត.ក/អ.ជ.ស.ដ, ចុះថ្ងៃទី១៧ មករា ២០១១, E9 ។

[3] នៅដំណាក់កាលនេះ សហព្រះរាជអាជ្ញា មិនមានលទ្ធភាពផ្តល់ជូននូវព័ត៌មានដូចដែលគ្រប់ឯកសារទាំងអស់របស់អ្នកជំនាញ សាក្សី ឬដើមបណ្តឹងរដ្ឋប្បវេណី ត្រូវបានយោងនៅក្នុងសក្ខីកម្មរបស់ពួកគេនោះទេ ។

ដែលគេរំពឹងថាបុគ្គលម្នាក់ៗនឹងស្បថ ឬមួយក៏កាលណាមានទំនាក់ទំនងរបស់ពួកគេទៅនឹងបុគ្គលទាំងនោះ ដូចដែលបានចែងនៅក្នុងវិធាន ២៤.២ នៃវិធានផ្ទៃក្នុង[4] ដែលនៅក្នុងករណីនេះបានច្រានចោលពួកគេជាមុនមិនឲ្យធ្វើសម្បថទេ, ភាសារបស់បុគ្គលដែលគេរំពឹងទុក ក្នុងការផ្តល់សក្ខីកម្ម និងរយៈពេលដែលគេប៉ាន់ស្មានតម្រូវទុកសម្រាប់ឲ្យផ្តល់សក្ខីកម្ម ។

*វិធានការការពារ*

៣. **ឧបសម្ព័ន្ធទី៣ក មានផ្ទុកនូវឈ្មោះលម្អិតរបស់សាក្សី ដែលសហព្រះរាជអាជ្ញា ជឿជាក់ថានឹងត្រូវស្នើឲ្យមាននូវវិធានការការពារ។ ឧបសម្ព័ន្ធទី២, ទី៣ និង ទី៤** មិនមានផ្ទុកទៅដោយព័ត៌មានពាក់ព័ន្ធទៅនឹងវិធានការការពារទេ ដែលវិធានការការពារទាំងនេះអាចនឹងត្រូវបានស្នើសុំដោយបុគ្គលនានាដែលមានឈ្មោះនៅក្នុងបញ្ជីទាំងនោះ ។ ទោះបីជាព័ត៌មានខ្លះក្នុងចំណោមព័ត៌មានទាំងនេះ ត្រូវបានគេយល់ឃើញថាត្រូវបានប្រមូលដោយការិយាល័យសហចៅក្រមស៊ើបអង្កេតក៏ដោយ ក៏វាពុំត្រូវបានគេដាក់នៅក្នុងសំណុំរឿងទេ ដែលជាហេតុធ្វើឲ្យសហព្រះរាជអាជ្ញាមិនអាចរកបាននូវព័ត៌មានទាំងនោះទេ ។ អនុលោមតាមមាត្រា ៣៣ថ្មី នៃច្បាប់អ.វ.ត.ក និងវិធាន ២៩.៣ នៃវិធានផ្ទៃក្នុង ដោយអាស្រ័យនូវអង្គហេតុពិតដែលថា សហព្រះរាជអាជ្ញាមិនធ្លាប់ដែលបានជួបប្រាស្រ័យជាមួយនឹងអ្នកជំនាញ សាក្សី និងដើមបណ្តឹងរដ្ឋប្បវេណីទាំងឡាយ។ សហព្រះរាជអាជ្ញាស្នើឲ្យអង្គជំនុំជម្រះសាលាដំបូង បង្គាប់ទៅអង្គភាពគាំពារសាក្សី និងអ្នកជំនាញ និងផ្នែកគាំពារជនរងគ្រោះ ដើម្បីឲ្យជួយដល់អង្គជំនុំជម្រះសាលាដំបូងក្នុងការកំណត់ថាតើ គេត្រូវស្វែងរកនូវវិធានការការពារសម្រាប់បុគ្គលនានាដែលមាននៅក្នុងបញ្ជីឈ្មោះរបស់សហព្រះរាជអាជ្ញា ដែរឬមួយយ៉ាងណា ។ សហព្រះរាជអាជ្ញាក៏ស្នើផងដែរថា អង្គភាពទាំងនេះត្រូវទទួលបាននូវព័ត៌មានជាក់លាក់ពីអ្នកជំនាញ សាក្សី ឬ ដើមបណ្តឹងរដ្ឋប្បវេណីនីមួយៗ អំពីប្រភេទនៃការការពារដែលពួកគេត្រូវការជាចាំបាច់នោះ ។

៤. អនុលោមតាមមាត្រា៧ នៃសេចក្តីណែនាំអនុវត្តស្តីពីការចាត់ថ្នាក់ឯកសារ និងការគ្រប់គ្រងព័ត៌មានទាក់ទងនឹងសំណុំរឿង ដើម្បីជួយការពារចំពោះការព្រួយបារម្ភណាមួយអំពីផ្នែកសន្តិសុខដែល អ្នកជំនាញ សាក្សី ឬដើមបណ្តឹងរដ្ឋប្បវេណីណាម្នាក់អាចនឹងមាននៅមុនពេលធ្វើការស្តាប់ចម្លើយផ្សេងៗ ដែលអង្គជំនុំជម្រះសាលាដំបូង អាចនឹងធ្វើឡើងជាមួយនឹងអង្គភាពគាំពារសាក្សី អ្នកជំនាញ និង

[4] វិធានផ្ទៃក្នុងអ.វ.ត.ក., វិធាន ២៤.២ ។

ជនរងគ្រោះ ពាក់ព័ន្ធនឹងវិធានការការពារ។ សហព្រះរាជអាជ្ញា បានដាក់រហស្សនាម ឱ្យជនម្នាក់ៗ ដែលមាននៅក្នុងបញ្ជីឈ្មោះនោះ។ សូមស្នើឱ្យប្រើរហស្សនាមទាំងនេះនៅក្នុងពេលដំណើរការនីតិវិធីទាំងមូល រហូតទាល់តែអង្គជំនុំជម្រះសាលាដំបូងបានធ្វើការកំណត់មួយពាក់ព័ន្ធនឹងភាពចាំបាច់នៃវិធានការការពារ ។ នេះគឺជាការជួយការពារជាមុនដល់ផលប្រយោជន៍ផ្នែក សន្តិសុខជាសក្តានុពលរបស់ពួកគេ ។ រហស្សនាមទាំងនេះត្រូវបានសំគាល់ ដោយអក្សរ “P” ហើយដែលមានបីខ្ទង់បន្តពីក្រោយវាទៀត ឧទាហរណ៍ដូចជា P-001 ។ រហស្សនាមទាំងនេះ ត្រូវបានដាក់តាមលំដាប់លេខរៀង ទៅតាមលំដាប់លំដោយដែលសហព្រះរាជអាជ្ញាដាក់ជូនដោយមានសំណើសុំថាឱ្យអ្នកជំនាញ សាក្សី ឬ ដើមបណ្តឹងរដ្ឋប្បវេណីទាំងនោះចូលបង្ហាញខ្លួននៅក្នុងពេលសវនាការ ។

## *ការធ្វើសម្បថ ឬ ការពោលតែពាក្យពិត*

៥. នៅពេលណាដែលអាចធ្វើទៅបាន សហព្រះរាជអាជ្ញាបានរួមបញ្ចូលនូវប្រភេទសម្បថ ឬការពោលតែពាក្យពិត ដែលអ្នកជំនាញ និងសាក្សី នឹងត្រូវធ្វើនៅក្នុងពេលសវនាការ ។ ទោះជាយ៉ាងនេះក្តី ជាទូទៅ ព័ត៌មាននេះមិនអាចរកបានទេ ។ ខណៈដែលកំណត់ហេតុស្តាប់ចម្លើយសាក្សីដែលការិយាល័យសហចៅក្រមស៊ើបអង្កេតបានធ្វើ ដែលជាទូទៅបញ្ជាក់អំពីថាតើ បុគ្គលនោះបានធ្វើសម្បថ ឬបានពោលតែពាក្យពិត ត្រូវទៅតាមវិធាន៣១ ឬ វិធាន២៤.១ កំណត់ហេតុនោះមិនបានបញ្ជាក់ពីប្រភេទនៃសម្បថដែលបានធ្វើនោះទេ ។ បន្ថែមលើនេះ បុគ្គលទាំងអស់ដែលមិនត្រូវបានស្តាប់ចម្លើយដោយការិយាល័យសហចៅក្រមស៊ើបអង្កេត គឺមិនទាន់ត្រូវបានគេតម្រូវឱ្យធ្វើសម្បថនៅឡើយទេ ។ ការធ្វើដូចនេះ រហូតមកទល់បច្ចុប្បន្នគឺមិនទាន់ដឹង អំពីចំណង់ចំណូលចិត្តរបស់ពួកគេនៅក្នុងការធ្វើសម្បថនៅឡើយទេ ។

៦. ទាក់ទិនទៅនឹងវិធាន៨០.១ នៃវិធានផ្ទៃក្នុង សហព្រះរាជអាជ្ញាក៏បានកត់សម្គាល់ផងដែរថា ខ្លួនមិនអាចមានមធ្យោបាយគ្រប់គ្រាន់ក្នុងការរកបាននូវព័ត៌មានដើម្បីអនុញ្ញាតឱ្យខ្លួនបានធ្វើការដាក់បង្ហាញថា តើសាក្សីទាំងឡាយនោះមានទំនាក់ទំនងជាមួយនឹងដើមបណ្តឹងរដ្ឋប្បវេណីដែរឬទេ ដែលនឹងប្រាប់ពួកគេ ចោលជាមុនពីការធ្វើសម្បថទៅតាមវិធាន២៤.២ ។ ហេតុផលសម្រាប់រោះងនេះគឺថាដើមបណ្តឹងរដ្ឋប្បវេណីភាគច្រើននៅក្នុងសំណុំរឿងលេខ ០០២ មិនត្រូវបានអនុញ្ញាតនិងកំណត់អត្តសញ្ញាណដោយ សហចៅក្រមស៊ើបអង្កេតទេ រហូតទាល់តែក្រោយពេលបានស្តាប់ចម្លើយសាក្សីទើបត្រូវបានអនុញ្ញាតនិងកំណត់អត្តសញ្ញាណ។ ព្រោះហេតុដូច្នោះហើយទើបបានជានៅ

ពេលដែលគេធ្វើការស្តាប់ចម្លើយសាក្សីទាំងនោះនៅក្នុងអំឡុងពេលនៃការស៊ើបសួរ វាពុំមានបញ្ជីឈ្មោះដើមបណ្តឹងរដ្ឋប្បវេណីដែលថាបានទទួលយកនោះ អាចនឹងត្រូវបានបង្ហាញដល់ពួកគេដើម្បីធ្វើការកំណត់ថាតើ វាមានទំនាក់ទំនងនឹងគ្នាបែបណាមួយដែរឬទេ ។ ហេតុដូច្នេះ សហព្រះរាជ-អាជ្ញា ក៏សូមលើកឡើងផងដែរថា សូមឱ្យអង្គជំនុំជម្រះសាលាដំបូងស្នើសុំជំនួយពី អង្គភាពគាំពារសាក្សី និងអ្នកជំនាញ ក្នុងគោលបំណងដើម្បីធ្វើការកំណត់ថាតើសាក្សីទាំងឡាយ ដែលមាននៅក្នុងបញ្ជីឈ្មោះ ដែលបានភ្ជាប់មកនេះមានទំនាក់ទំនងទៅនឹងដើមបណ្តឹងរដ្ឋប្បវេណីដែលថាបានទទួលយក ទាំងនោះ ។

***ការប៉ាន់ប្រមាណអំពីពេលវេលា***

៧. ការប៉ាន់ប្រមាណអំពីពេលវេលាត្រូវបានកំណត់ដោយឈរលើមូលដ្ឋានដែល សហព្រះរាជអាជ្ញា អាចសួរសំណួរទៅអ្នកជំនាញ ដើមបណ្តឹងរដ្ឋប្បវេណី ឬ សាក្សី យ៉ាងហោចណាស់ក៏ត្រូវចំណាយមួយភាគបីនៃពេលវេលាដែលគេប៉ាន់ប្រមាណសម្រាប់ការផ្តល់សក្ខីកម្មទាំងមូល។

## ៣. ការពិចារណានៅក្នុងការជ្រើសរើស

៨. សហព្រះរាជអាជ្ញា បានស្នើឱ្យមានបញ្ជីឈ្មោះអ្នកជំនាញ សាក្សី និងដើមបណ្តឹងរដ្ឋប្បវេណីរបស់ខ្លួនសម្រាប់សំណុំរឿងនេះ ក្នុងគោលបំណងដើម្បីធ្វើការថ្លឹងថ្លែងអំពីការស្វែងរកនូវការពិតនៃអង្គហេតុទាំងឡាយដែលបានចោទប្រកាន់នៅក្នុងដីកាដំណោះស្រាយ, ការការពារនូវសិទ្ធិរបស់ជនជាប់ចោទក្នុងការទទួលបាននូវការកាត់សេចក្តីមួយដ៏ត្រឹមត្រូវ និងការជួយសម្រួលអំពីភាពចាំបាច់ក្នុងការសន្សំសំចៃថវិការរបស់តុលាការ ។ យ៉ាងហោចណាស់ក៏ សក្ខីកម្មរបស់ជនទាំងនេះនឹងក្លាយទៅជាស្នូលដែលបង្គលក្ខណៈឱ្យសហព្រះរាជអាជ្ញា មានលទ្ធភាពដើម្បីបង្ហាញភស្តុតាងអំពីទ្រង់ទ្រាយដ៏ធំធេងនៃឧក្រិដ្ឋកម្មនានា និងអំពីទម្រង់ផ្សេងៗនៃការទទួលខុសត្រូវជាបុគ្គលខាងព្រហ្មទណ្ឌដែលបានចោទប្រកាន់ នៅក្នុងដីកាដំណោះស្រាយឱ្យបានហួសពីវិមតិសង្ស័យ ដូចដែលត្រូវបានតម្រូវដោយវិធាន៨៧.១ នៃវិធានផ្ទៃក្នុង ។

៩. សូមបញ្ជាក់ថា ក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះមានការចោទប្រកាន់អំពីឧក្រិដ្ឋកម្មជាច្រើនដោយផ្អែកលើមូលដ្ឋាននៃព្រឹត្តការណ៍ព្រហ្មទណ្ឌទ្រង់ទ្រាយធំជាច្រើននានាដែលមានលក្ខណៈស្មុគស្មាញដែលកើតមានឡើងក្នុងអម្លុងពេលតែជិតបួនឆ្នាំប៉ុណ្ណោះ ក៏ដូចជាតំណភ្ជាប់ដោយផ្ទាល់ និង ដោយប្រយោលរវាងសកម្មភាពនានារបស់ជនជាប់ចោទ និងការកើតមានឡើងនៃឧក្រិដ្ឋកម្មទាំងនោះ

ហើយនិងព្រឹត្តិការណ៍ខក្រិដ្ឋនានា សហព្រះរាជអាជ្ញាសន្និដ្ឋានថាចំនួនសរុបនៃបុគ្គលទាំងអស់ដែលបានដាក់បញ្ចូលនៅក្នុងបញ្ជីអ្នកជំនាញ សាក្សី និង ដើមបណ្តឹងរដ្ឋប្បវេណីរបស់សហព្រះរាជអាជ្ញា គឺតំណាងឱ្យសមាមាត្រដ៏តូចមួយរៀងៗខ្លួនតែប៉ុណ្ណោះពីក្នុងចំណោម បុគ្គលទាំងឡាយដែលមានការគាំទ្រដល់ការចោទប្រកាន់នានានៅក្នុងដីកាដំណោះស្រាយ ដែលមួយវិញទៀត អាចថានឹងត្រូវបានកោះហៅឱ្យមកផ្តល់សក្ខីកម្ម ។

១០. បុគ្គលផ្សេងៗទៀត គឺមិនទាន់បានដាក់បញ្ចូលឈ្មោះក្នុងបញ្ជីនៅឡើយទេដោយផ្អែកលើមូលដ្ឋានថាសហព្រះរាជអាជ្ញានឹងត្រូវបានអនុញ្ញាតឱ្យបញ្ចូលជាភស្តុតាងនូវចម្លើយរបស់សាក្សីនានាព្រមទាំងឯកសារពាក់ព័ន្ធផ្សេងៗអនុលោមតាមវិធាន៨៧ នៃវិធានផ្ទៃក្នុង ។ ក្នុងករណីបើសិនជាចម្លើយរបស់សាក្សីនានានិងឯកសារពាក់ព័ន្ធផ្សេងៗមិនត្រូវបានយល់ព្រមទទួលយកទេនោះ សហព្រះរាជអាជ្ញាសូមជូនដំណឹងដល់អង្គជំនុំជម្រះសាលាដំបូងឱ្យបានជ្រាបថា ខ្លួនអាចនឹងធ្វើសុំណើសុំបន្ថែមទៀតនូវអ្នកជំនាញ សាក្សី ឬដើមបណ្តឹងរដ្ឋប្បវេណីដែលត្រូវកោះហៅឱ្យចូលបង្ហាញខ្លួននៅក្នុងសវនាការ បើសិនជាតាមការយោបល់របស់សហព្រះរាជអាជ្ញាយល់ថា ការដកចេញនូវឯកសារភស្តុតាងបែបនេះ ជាការធ្វើឱ្យខូចដល់លទ្ធភាពរបស់ខ្លួនក្នុងការបំពេញឱ្យបានគ្រប់គ្រាន់ទៅតាមលក្ខខណ្ឌតម្រូវនៃបទដ្ឋានស្តីពីភស្តុតាងលើបញ្ហាទាក់ទងទៅនឹងឯកសារដោយឡែកណាមួយ ក្នុងសំណុំរឿងនេះ។

១១. ជាឧទាហរណ៍ សហព្រះរាជអាជ្ញាមិនបានដាក់បញ្ចូលនូវបុគ្គលទាំងអស់ដែលអាចជួយបាននៅក្នុងការបញ្ជាក់យថាភូតលើឯកសារពាក់ព័ន្ធដែលនឹងត្រូវស្វែងរកសុំឱ្យយល់ព្រមទទួលយកនោះទេ ។ ទោះជាយ៉ាងណាក្តី បើសិនជាមេធាវីការពារក្តីប្រឆាំងតវ៉ាអំពីយថាភូតលើភស្តុតាង ហើយអង្គជំនុំជម្រះសាលាដំបូង កំណត់ថាតម្រូវឱ្យមានការបញ្ជាក់យថាភូតលើឯកសារបែបដូច្នោះនៅពេលក្រោយទៀត សហព្រះរាជអាជ្ញា សូមជូនដំណឹងដល់អង្គជំនុំជម្រះសាលាដំបូងថាខ្លួននឹងធ្វើ សំណើសុំឱ្យកោះហៅសាក្សីបន្ថែមនានាដែលត្រូវបញ្ជាក់យថាភូតទាំងនេះ។ **ឧបសម្ព័ន្ធទី៥** មានផ្ទុកទៅដោយឈ្មោះរបស់បុគ្គលបែបដូច្នោះមួយចំនួន។

១២. ស្រដៀងគ្នានេះដែរ កាលណាអ្នកជំនាញ សាក្សី ឬដើមបណ្តឹងរដ្ឋប្បវេណីដែលបានកំណត់អត្តសញ្ញាណនៅក្នុងបញ្ជីឈ្មោះក្នុងឧបសម្ព័ន្ធទាំងនេះ មិនអាចបង្ហាញខ្លួននៅពេលសវនាការបានដោយសារហេតុផលណាមួយក៏ដោយ ឬមួយក៏ពួកគេបានមកបង្ហាញខ្លួននៅពេលសវនាការ តែមិន

អាចមានលទ្ធភាពរៀបរាប់ពីអង្គហេតុដែលមាននៅក្នុងចម្លើយជាលាយលក្ខអក្សររបស់ខ្លួនបាន នោះសហព្រះរាជអាជ្ញា ផ្តល់ការជូនដំណឹងផងដែរដល់អង្គជំនុំជម្រះសាលាដំបូងថាខ្លួនអាចស្នើឱ្យសុំកោះហៅអ្នកជំនាញ សាក្សី ឬដើមបណ្តឹងរដ្ឋប្បវេណីជំនួស ឱ្យចូលមកបង្ហាញខ្លួនដើម្បីផ្តល់ សក្ខីកម្មលើបញ្ហាដូចគ្នា ឬស្រដៀងគ្នានោះ ។ ជាទូទៅជាងនេះទៀត នៅពេលដែលសវនាការកំពុង ដំណើរការ បើសហព្រះរាជអាជ្ញាជឿជាក់ថាមានការចាំបាច់ត្រូវហៅសាក្សីក្រោយៗឱ្យមកបំភ្លឺ ដែលសហព្រះរាជអាជ្ញាផ្តល់ការជូនដំណឹងដល់អង្គជំនុំជម្រះសាលាដំបូងថាខ្លួននឹងធ្វើសំណើនេះ នៅពេលដែលខ្លួនមានការជឿជាក់ដូច្នេះ ។

១៣. មានបុគ្គលមួយចំនួនតូចប៉ុណ្ណោះ ដែលសហចៅក្រមស៊ើបអង្កេតនៅមិនទាន់បានធ្វើការស្តាប់ចម្លើយ ហើយដែលសហព្រះរាជអាជ្ញាចង់ឱ្យធ្វើការកោះហៅមកនៅចំពោះមុខអង្គជំនុំជម្រះនេះ។ បុគ្គលទាំងនោះរួមមានភាគច្រើនជាអ្នកជំនាញដែលមាននៅក្នុងបញ្ជីឈ្មោះនៅក្នុង **ឧបសម្ព័ន្ធទី២**។ ជាការជាក់ស្តែង ការិយាល័យសហចៅក្រមស៊ើបអង្កេត មិនបានស្តាប់ចម្លើយបុគ្គលនានាដែលធ្លាប់ត្រូវបានគេដឹងយ៉ាងទូលំទូលាយរួចមកហើយស្តីពីបញ្ហានានាដែលទាក់ទងនិងកម្មវត្ថុនៃរឿងក្តីដែលនៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះ។ ក៏ប៉ុន្តែ ការចុះផ្សាយអំពីបុគ្គលទាំងនេះបែរជាត្រូវបានដាក់ចូលទៅក្នុងសំណុំរឿងទៅវិញ ។ អង្គហេតុពិតដែលថាអ្នកជំនាញ ឬសាក្សី ទាំងនេះមិនបានបង្ហាញសក្ខីកម្មនៅចំពោះមុខសហចៅក្រមស៊ើបអង្កេត មិនបានកាត់បន្ថយតម្លៃនៃសក្ខីកម្មរបស់ពួកគេទេ ។ តាមពិតទៅ បុគ្គលនីមួយៗទាំងនោះគឺស្ថិតនៅក្នុងឋានៈមួយដែលអាចផ្តល់ជូននូវទស្សនៈដែលមានលក្ខណៈទោលបាន (unique insight) ដែលជាញឹកញាប់ គឺនៅលើបញ្ហានានា យ៉ាងច្រើនដែលជាប់ទាក់ទងសមហេតុផលទៅនឹងសំណុំរឿងនេះ ហើយដែលមានលក្ខណៈច្បាស់លាស់ខ្លីៗ ដែលនាំឱ្យមានការចំណេញដល់ថវិការបស់អង្គជំនុំជម្រះផង។ បន្ថែមលើនេះ កាលណាសហព្រះរាជអាជ្ញាបានធ្វើការកោះហៅសាក្សី (**ឧបសម្ពន្ធទី៣**) ឬ ដើមបណ្តឹងរដ្ឋប្បវេណី (**ឧបសម្ពន្ធទី៤**) ដែលការិយាល័យសហចៅក្រមស៊ើបអង្កេតមិនទាន់បានស្តាប់ចម្លើយនោះ គឺសហព្រះរាជអាជ្ញាបានធ្វើយ៉ាងដូច្នេះដោយមានការជឿជាក់ថា សក្ខីកម្មរបស់បុគ្គលទាំងនេះមានលក្ខណៈជាប់ទាក់ទងសមហេតុផលយ៉ាងជាក់លាក់ទៅនឹងការបង្ហាញភស្តុតាង អំពីអង្គហេតុសំខាន់ៗជាគន្លិះ។

១៤. ទាក់ទងនឹងដើមបណ្តឹងរដ្ឋប្បវេណីដែលបានកំណត់អត្តសញ្ញាណនៅក្នុង **ឧបសម្ពន្ធទី៤** រួចហើយ សហព្រះរាជអាជ្ញា នឹងធ្វើការស្វែងរកកោះហៅបុគ្គលទាំងនេះ និងសុំអនុញ្ញាត សួរសំណួរដល់ពួក

គេនៅពេលសវនាការ ។ បន្ថែមលើនេះ សហព្រះរាជអាជ្ញា ស្វែងរកធ្វើការសួរ សំណួរដល់បុគ្គលទាំងនេះតាមរបៀបជាសាក្សីធម្មតា បើពួកគេលះបង់ចោលនូវការស្នើសុំធ្វើជា ដើមបណ្តឹងរដ្ឋប្បវេណីដូចដែលវិធាន *២៣ស្ទួនប្រាំ* នៃវិធានផ្ទៃក្នុងបានអនុញ្ញាត ឬបើតាមបែប ផ្សេងនោះគឺ អង្គជំនុំជម្រះសាលាដំបូងធ្វើការកំណត់ថាវាជាការមួយដ៏ត្រឹមត្រូវដែលថាបុគ្គលបែបដូច្នោះត្រូវផ្តល់សក្ខីកម្មក្នុងឋានៈជាសាក្សីធម្មតា ។

## ៤. សំណើសុំឲ្យកោះហៅសាក្សីតាមលេខរៀងសម្រាប់សវនាការ

១៥. នៅក្នុង **ឧបសម្ព័ន្ធទី១** សហព្រះរាជអាជ្ញាបានដាក់ជូននូវដាប់លំដោយលេខរៀងដែលអ្នកជំនាញ សាក្សី និងដើមបណ្តឹងរដ្ឋប្បវេណី ត្រូវបានកោះហៅឲ្យមកបង្ហាញខ្លួននៅពេលសវនាការ ដែលក្នុងនោះបញ្ហាជាគន្លឹះនានានិងវិស័យនានាដូចនៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះគួរបានលើកមកបង្ហាញជូន។ សហព្រះរាជអាជ្ញា សូមស្នើជាក្រុម និងសួរជាសំណួរដល់អ្នកជំនាញ សាក្សី និង ដើមបណ្តឹងរដ្ឋប្បវេណី ទៅតាមបញ្ហាដែលបានចោទប្រកាន់ពីដំបូង ឬទៅតាមព្រឹត្តិការណ៍ឧក្រិដ្ឋកម្មដែលពួកគេអាចមានលទ្ធភាពនឹងផ្តល់សក្ខីកម្មបាន ។

១៦. ប្រាកដណាស់ថា សហព្រះរាជអាជ្ញាទទួលស្គាល់ថា អ្នកជំនាញ សាក្សី និងភាគីដើមបណ្តឹងរដ្ឋប្បវេណីជាច្រើន នឹងផ្តល់ភស្តុតាងដែលជាប់ទាក់ទិននឹងបញ្ហាជាច្រើន និងព្រឹត្តិការណ៍ឧក្រិដ្ឋកម្មនានាផងដែរ ។ ដើម្បីជៀសវាងការបង្ហាញខ្លួនរបស់បុគ្គលម្នាក់ៗច្រើនលើកច្រើនសារ ឬត្រូវបែងចែកជាផ្នែកៗនូវសក្ខីកម្មរបស់ពួកគេដែលជាការមិនចាំបាច់នោះ សហព្រះរាជអាជ្ញាសូមស្នើថាគូភាគី អាចសួរទៅកាន់ បុគ្គលនីមួយៗទាំងនោះគ្រប់បញ្ហា និងព្រឹត្តិការណ៍ឧក្រិដ្ឋកម្មទាំងអស់ដែលពួកគាត់អាចឆ្លើយបំភ្លឺបាន។ យ៉ាងណាក៏ដោយ សហព្រះរាជអាជ្ញាស្នើថា សំណើរបស់ខ្លួនសម្រាប់គ្រោងការរួមនៃការធ្វើបទបង្ហាញភស្តុតាងនេះ នឹងត្រូវបានរក្សាទុកដើម្បីជាការផ្តល់ជូនដល់អង្គជំនុំជម្រះសាលាដំបូង និងសាធារណៈជនទូទៅនូវលទ្ធភាពយល់ដឹងឲ្យបានល្អបំផុតតាមដែលអាចធ្វើទៅបានអំពីសំណុំរឿង និងលើកកំពស់ប្រសិទ្ធផលនៅក្នុងការធ្វើបទបង្ហាញរបស់ខ្លួនដោយគូភាគីនានា។

### *ដំណាក់កាលទី១*

១៧. សហព្រះរាជអាជ្ញា បានស្នើឲ្យចាប់ផ្តើមបើកសវនាការជំនុំជម្រះក្តីលើព្រឹត្តការណ៍នានាជាគន្លឹះ និងលើឧក្រិដ្ឋកម្មនានាដែលបានចោទប្រកាន់ដែលបានកើតឡើងកាលពីថ្ងៃទី១៧ ខែមេសា ឆ្នាំ

១៩៧៥ និងនៅថ្ងៃជាបន្តក្រោយៗមកទៀត ជាក់ស្តែងគឺការជម្លៀសប្រជាជនចេញដោយបង្ខំពីទីក្រុងភ្នំពេញ និងការប្រហារជីវិតក្នុងទ្រង់ទ្រាយធំចំពោះពួកមន្ត្រីនានា និងពួកទាហាននៃរដ្ឋាភិបាលរបបសាធារណរដ្ឋខ្មែរព្រមទាំងអ្នកជម្លៀសដទៃទៀត ដែលរួមមាន ទីតាំងឧក្រិដ្ឋកម្មទួលពោធិ៍ជ្រៃ និងស្រុក១២ (**ឧបសម្ព័ន្ធទី ១, ផ្នែកទី១ ដល់ ៣**) ។

### *ដំណាក់កាលទី២*

១៨. បន្ទាប់ពីនេះ សហព្រះរាជអាជ្ញា នឹងស្នើឲ្យពិនិត្យមើលលើការបង្កើតរបបកម្ពុជាប្រជាធិបតេយ្យ តួនាទីរបស់ជនជាប់ចោទ គោលនយោបាយរបស់បក្សកុម្មុយនីស្តកម្ពុជា ហើយនិងសហកម្មឧក្រិដ្ឋកម្មរួមដែលត្រូវបានអនុវត្តនៅក្នុងអម្លុងពេលនៃរបបនេះ ដែលរួមមានសេចក្តីពិពណ៌នាទូទៅដោយត្រួសៗ អំពីប្រវត្តិនិងគោលនយោបាយ និងរចនាសម្ព័ន្ធចាត់តាំងរបស់មជ្ឈិមបក្ស, របស់ភូមិភាគនានា, យោធា និងបណ្តាក្រសួងនានារបស់រដ្ឋាភិបាល, រចនាសម្ព័ន្ធនៃការទាក់ទងគ្នាទៅវិញទៅមក ហើយនិងការអប់រំខាងនយោបាយ ដែលតាមរយៈនេះសហកម្មឧក្រិដ្ឋកម្មរួមនិងគោលនយោបាយរបស់បក្សកុម្មុយនិស្តកម្ពុជា (បកក) ត្រូវបានអនុវត្ត ព្រមទាំងការបោសសំអាតនៅតាមអង្គការនានារបស់កម្ពុជាប្រជាធិបតេយ្យ និង បកក ដែលធ្វើឡើងដោយមេដឹកនាំជាន់ខ្ពស់ (**ឧបសម្ព័ន្ធទី១ ផ្នែកទី៤ ដល់ ១៥**) ។

### *ដំណាក់កាលទី៣*

១៩. ដំណាក់កាលបន្ទាប់ និងជាចុងក្រោយនៃសវនាការជំនុំជម្រះក្តី ដែលបានស្នើដោយសហព្រះរាជ-អាជ្ញានៅក្នុង**ឧបសម្ព័ន្ធទី១** នោះគឺសំដៅទៅលើ ទីតាំង និងព្រឹត្តការណ៍ឧក្រិដ្ឋកម្មជាក់លាក់នានា ដែលមានទំហំធំ ហើយដែលបានដាក់បញ្ចូលនៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះ ដែលចាប់ផ្តើមពីអត្ថិភាពនៃជម្លោះប្រដាប់អាវុធ (ផ្នែកទី១៦), មណ្ឌលសន្តិសុខនានា និង ទីកន្លែងដែលពាក់ព័ន្ធ (ផ្នែកទី១៧ ដល់២៩), ការធ្វើបាបពុទ្ធសាសនិកជន(ផ្នែកទី៣០), ការធ្វើបាបជនជាតិចាម (ផ្នែកទី៣១), ការឲ្យរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ (ផ្នែកទី៣២), ការជម្លៀសប្រជាជនដោយបង្ខំលើកទី២ (ផ្នែកទី៣៣), ការដ្ឋានពលកម្មធ្វើការដោយបង្ខំនានា (ផ្នែកទី៣៤ ដល់៣៧), ការធ្វើបាបជនជាតិវៀតណាម (ផ្នែកទី៣៨), ការបោសសំអាតនៅភូមិភាគបូព៌ា ដែលរួមបញ្ចូល កន្លែងប្រហារជីវិតនៅស្ទឹងតូច ការជម្លៀសប្រជាជនដោយបង្ខំចេញពីភូមិភាគបូព៌ា និងការសម្លាប់ប្រជាជនជម្លៀសក្នុងទ្រង់ទ្រាយធំ (ផ្នែកទី៣៩ ដល់៤១), និងការពិពណ៌នាទូទៅដោយត្រួសៗអំពីឧក្រិដ្ឋកម្មនានា (ផ្នែកទី៤២)។

២០. ដោយអនុលោមតាមវិធាន ៨០.២ នៃវិធានផ្ទៃក្នុង សហព្រះរាជអាជ្ញាយល់ថា ភាគីដើមបណ្តឹងរដ្ឋប្បវេណី និងមេធាវីការពារក្តី អាចដាក់សំណើផ្ទាល់ខ្លួនសម្រាប់សាក្សី ដើម្បីចូលខ្លួននៅពេលសវនាការ។ ដើម្បីជាប្រយោជន៍នៃភាពច្បាស់លាស់ ប្រសិទ្ធផល និងយុត្តិធម៌ សហព្រះរាជអាជ្ញាសូមស្នើថា សាក្សីទាំងនោះនឹងត្រូវបានវាយតម្លៃស្របតាមបញ្ហាជាគន្លឹះ និងព្រឹត្តិការណ៍ឧក្រិដ្ឋកម្មនានាដែលពួកគាត់អាចឆ្លើយបំភ្លឺបាន និងស្នើឱ្យពួកគាត់ចូលបង្ហាញខ្លួនដើម្បីផ្តល់ចម្លើយស្របតាមបញ្ហា ឬទីតាំងចំបងដែលពួកគាត់អាចផ្តល់ភស្តុតាងបាន ដើម្បីឱ្យគ្រោងការរួមសម្រាប់ការធ្វើបទបង្ហាញភស្តុតាងនេះដែលបានស្នើឡើងដោយសហព្រះរាជអាជ្ញានោះ ត្រូវបានរក្សាទុកដដែល ។

## ៥. សំណើ

២១. អាស្រ័យហេតុដូច្នេះ សហព្រះរាជអាជ្ញា សូមស្នើថា៖

១). បន្ទាប់ពីសម្រេចលើកាលវិភាគរួចហើយនោះ សូមឱ្យធ្វើការកោះហៅសាក្សី ដើមបណ្តឹងរដ្ឋប្បវេណី និងអ្នកជំនាញទាំងឡាយដូចដែលបានបញ្ជាក់អត្តសញ្ញាណក្នុង**ឧបសម្ពន្ធទី២, ទី៣, ទី៣ក និង ទី៤** ដើម្បីឱ្យចូលខ្លួនមកផ្តល់ភស្តុតាង នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង ដោយអនុលោមតាមវិធាន៨៤.២ ។

២). សូមឱ្យអង្គជំនុំជម្រះសាលាដំបូងចេញដីកាបង្គាប់ឱ្យអង្គភាពគាំពារសាក្សី និងអ្នកជំនាញ និងផ្នែកគាំពារជនរងគ្រោះ ផ្តល់នូវព័ត៌មានទាំងឡាយដែលចាំបាច់ មកឱ្យអង្គជំនុំជម្រះសាលាដំបូង ដើម្បីឱ្យអង្គជំនុំជម្រះសាលាដំបូង ធ្វើការកំណត់ថា តើមានភាពចាំបាច់ ដើម្បីផ្តល់វិធានការការពារដល់អ្នកជំនាញ សាក្សី និងដើមបណ្តឹងរដ្ឋប្បវេណីទាំងនេះ នៅក្នុងទូទាំងដំណើរការនីតិវិធីទាំងមូល ដោយអនុលោមតាមវិធាន ៣៣ថ្មី និងវិធាន ២៩ នៃវិធានផ្ទៃក្នុងដែរឬយ៉ាងណា៕

| កាលបរិច្ឆេទ | ឈ្មោះ | ទីកន្លែង | ហត្ថលេខា |
|---|---|---|---|
| ថ្ងៃទី២៨ ខែមករា ឆ្នាំ២០១១ | **លោកស្រី ជា លាង**<br>សហព្រះរាជអាជ្ញា | ភ្នំពេញ | |
| | **លោក** Andrew CAYLEY<br>សហព្រះរាជអាជ្ញា | | |